ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០១៧.១៨៩.ធក.សណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការចេញផ្សាយមូលបត្រអាចជួញដូរបាន

ក្នុងគោលបំណងសម្រួលដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការជាវមូលបត្រអាចជួញដូរបាន (NCD) ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមជូនដំណឹងដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងចេញផ្សាយមូលបត្រអាចជួញដូរបានមួយលើកក្នុងមួយសប្តាហ៍ គឺនៅថ្ងៃព្រហស្បតិ៍ ហើយនឹងទទួលពាក្យសុំជាវនៅថ្ងៃពុធ ចាប់ពីម៉ោង ៨:០០ រហូតដល់ ម៉ោង ១១:០០ ព្រឹក ដោយកំណត់ថ្ងៃទទួលពាក្យសុំជាវជាថ្ងៃប្រសិទ្ធភាពអត្រាការប្រាក់។

- ក្នុងករណីដែលថ្ងៃទទួលពាក្យសុំជាវ ត្រូវចំប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ ការទទួលពាក្យសុំជាវនឹងត្រូវលើកទៅមួយថ្ងៃធ្វើការ មុនប្រតិទិនឈប់សម្រាក។
- ក្នុងករណីដែលថ្ងៃចេញផ្សាយត្រូវចំប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ ថ្ងៃចេញផ្សាយនឹងត្រូវលើកទៅមួយថ្ងៃធ្វើការ ក្រោយប្រតិទិនឈប់សម្រាក។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជ្រាបនិងសហការអនុវត្ត។

រាជធានីភ្នំពេញ ថ្ងៃទី២៣ខែកុម្ភៈ ឆ្នាំ២០១៧

**អគ្គនាយកបច្ចេកទេស**

ជា សិរី

**កន្លែងទទួល**
- គ្រប់អគ្គនាយកដ្ឋាន "ដើម្បីជូនជ្រាប"
- នាយកដ្ឋានពាក់ព័ន្ធ
- គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ "ដើម្បីជ្រាបនិងសហការអនុវត្ត"